# កម្លាំងជាតិ

គឺជា អាពាហ៍ពិពាហ៍ នៃពលរដ្ឋម្នាក់ៗ និង ករណីកិច្ច នៃខ្លួន។ បើគ្មាន នូវសម្ពន្ធ ជាពាក្យប្រើប្រដូចនេះ គឺមិនមែនគ្រាន់តែជាដំណួល នៃប្រជារាស្ត្រ គឺវាជាការរលំ នៃមាតុភូមិតែម្តង។ ដូច្នេះ ប្រជារាស្ត្រ គឺជាមាតុភូមិ នៃប្រជាជាតិ មានកម្លាំងដ៏ល្អ ពោលថាជា ជញ្ជីង នៃកាយពល និង សីលធម៌ អោយមានសមតាទាំងអស់ ជាភាពបវរ។ ភាពបវរនេះ ជាមនសិការជាតិ ដែលប្រជាពលរដ្ឋខ្មែរ ធ្លាប់មាន ដែលមានទុកស្នាម នៅក្នុងប្រវត្តិសាស្ត្រជាតិ, ជាប្រពៃណីយោជាក្តី ជាសិល្បៈក្តី ជាអក្សរសាស្ត្រក្តី ជាការរស់នៅក្តី ទោះបីគេដឹងថា រាស្ត្រខ្មែរ ទទួលរងគ្រោះទុក្ខគ្រប់បែបយ៉ាង បន្តៗគ្នាជាលំដាប់ ពីសំណាក់របបដឹកនាំ មានធម្មជាតិយ៉ាងណាក្តី : គាត់មានទុក្ខក្រៃលែង។ តែបើជួនកាលមានការស្តីរំឭក ចំពោះរាស្ត្រខ្មែរ, សុំកំភ្លេចថា កាលណា ប្រជាជាតិ ត្រូវការរាស្ត្រ វាតែងតែមានវត្តមាន នៃគាត់ជានិច្ច ទោះបី យកគាត់ទៅប្រើ ជាឧបករណ៍បែបណាក៏ដោយ។ តើប្រជារាស្ត្រ មិនមែនជា កម្លាំងជាតិ ដូច្នោះទេឬ ? តែ អ្នកដឹកនាំ រមែងបំភ្លេច សិទ្ធិរបស់ប្រជាពលរដ្ឋជានិច្ច នៅពេលដែលខ្លួន មានអំណាចផ្តាច់មុខ និង សេចក្តីសុខស្រួលអាត្មា គឺនៅពេលពួកគាត់ ទទួលទានកាយាបរិបូរណ៍ ក៏ប៉ុន្តែ រាស្ត្រមួយនគរ គាត់រស់នៅ ស៊ីចុក ក្នុងសភាពអត្តខាត់ជាទីបំផុត។ កុំភ្លេចថា របបខ្មែរក្រហម យកកម្លាំងបក្ស ជំនួសកម្លាំងជាតិ, លទ្ធផល គឺទ័ពយួន វាយយកស្រុកខ្មែរបានស្រួលបំផុត៕

**ឧប សៅ សង្ហា** **គំនិត** **១៨ មិថុនា ២០១៥**